雲南日報
YUNNAN DAILY PRESS GROUP
云南日报报业集团
No.162

ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

khmerlight@163.com
english.yunnan.cn

ឆ្នាំទី 26 លេខ 7694 ថ្ងៃសុក្រ ទី 27 ខែ កក្កដា ឆ្នាំ 2018

គំនិតផ្តួចផ្តើម "ខ្សែក្រវាត់មួយ និងផ្លូវមួយ" ជួយកម្ពុជាកសាងប្រព័ន្ធបណ្តាញគមនាគមន៍ពេញលក្ខណៈ

"មានផ្លូវគឺមានសង្ឃឹម!" សុភាសិតខ្មែរនេះបានបង្ហាញឱ្យឃើញពីសារសំខាន់នៃការអភិវឌ្ឍប្រព័ន្ធបណ្តាញគមនាគមន៍ចំពោះប្រជាជនខ្មែរ ។ ក្នុងនាមជាប្រទេសសំខាន់មួយតាមបណ្តោយ "ខ្សែក្រវាត់មួយនិងផ្លូវមួយ" ប្រទេសកម្ពុជាបាននិងកំពុងខិតខំពង្រឹងកិច្ចសហប្រតិបត្តិការជាមួយប្រទេសចិននិងចូលរួមយ៉ាងសកម្មក្នុងការកសាង "ខ្សែក្រវាត់និងផ្លូវ" ដើម្បីបង្កើតបណ្តាញគមនាគមន៍ពេញលក្ខណៈដែលគ្របដណ្តប់លើផ្លូវថ្នល់កំពង់ផែនិងអាកាសចរណ៍ជាដើមព្រមទាំងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ចនៃប្រទេសកម្ពុជា ។

កាលពីថ្ងៃទី១ ខែកក្កដា ឆ្នាំ ២០១៨ ស្ពានអាកាសកម្ពុជា-ចិន សែនសុខ ត្រូវបានបើកដំណើរការ ។ ស្ពានអាកាសនេះ ត្រូវបានកសាងឡើង ក្រោមជំនួយដោយរដ្ឋាភិបាលចិន និង អនុវត្តន៍ការសាងសង់ដោយក្រុមហ៊ុន សំណង់ ស្ប៉េងហៃហ្គ្រុប (រូបថត ដោយ Yu Jiangning)

គម្រោងជួសជុលនិងសាងសង់បន្ថែមផ្លូវជាតិលេខ៣ ដែលផ្តល់ជំនួយសាងសង់ដោយប្រទេសចិននោះបានបើកការដ្ឋានសាងសង់នៅខែឧសភាឆ្នាំនេះ ។ អ្នកភូមិដែលរស់នៅក្បែរការដ្ឋានសាងសង់ក្នុងតំបន់ជាយក្រុងភ្នំពេញបានប្រាប់អ្នកកាសែតថា សព្វថ្ងៃគម្រោងសាងសង់បានចាប់ដំណើរការជាផ្លូវការរួចហើយ ។ នាពេលខាងមុខយើងនឹងមានផ្លូវកាន់តែទូលាយហើយធ្វើដំណើរទៅមកកាន់តែស្រួលនិងអាចងាយស្រួលដល់ការរកស៊ីរបស់យើង ។

គម្រោងផ្លូវជាតិលេខ៣នេះគ្រាន់តែជាគម្រោងមួយក្នុងចំណោមគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធដ៏ច្រើនសន្ធឹកសន្ធាប់ក្នុងប្រទេសកម្ពុជាដែលផ្តល់ជំនួយដោយប្រទេសចិន។ ក្នុងអំឡុងពេលពីដើមឆ្នាំនេះដល់សព្វថ្ងៃគម្រោងសាងសង់ផ្លូវលេខ១៥៧៧ និងផ្លូវលេខ ៦ បានត្រូវបញ្ចប់ការសាងសង់ជាស្ថាពរនិងត្រូវដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ។ ទន្ទឹមនឹងនេះនៅមានគម្រោងសាងសង់ថ្មីជាច្រើនបានចាប់ដំណើរការសាងសង់ជាបន្តបន្ទាប់ ។

លោក ស្យូង ពួ ឯកអគ្គរដ្ឋទូតប្រទេសចិនប្រចាំនៅប្រទេសកម្ពុជា បានមានប្រសាសន៍ថា ឆ្នាំនេះជាខួបលើកទី៤០នៃការអនុវត្តគោលនយោបាយកែទម្រង់និងបើកចំហ និងជាខួបទី៦០ឆ្នាំនៃការបង្កើតទំនាក់ទំនងការទូតចិននិងកម្ពុជា ។ ការរីកចម្រើនយ៉ាងឆាប់រហ័សនៃទំនាក់ទំនងចិននិងកម្ពុជាបានបង្កលក្ខណៈដល់ការពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ចពាណិជ្ជកម្ម និងវិនិយោគរវាងប្រទេសទាំងពីរ ។ កម្ពុជាបានក្លាយទៅជាទីដៅវិនិយោគដ៏សំខាន់មួយរបស់សហគ្រាសចិនក្រោមក្របខ័ណ្ឌនៃគំនិតផ្តួចផ្តើម "ខ្សែក្រវាត់មួយនិងផ្លូវមួយ" ។

គម្រោងសាងសង់ព្រលានយន្តហោះខេត្តសៀមរាបថ្មីដែលធ្វើវិនិយោគដោយក្រុមហ៊ុនវិនិយោគខេត្តយូនណានគ្រុបនោះកំពុងតែដំណើរការអនុវត្តយ៉ាងរលូនតាមរូបមន្ត។រយៈពេលនៃការសាងសង់ និងគ្រប់គ្រង គឺ ៥៥ឆ្នាំក្នុងនោះ មានរយៈពេលសាងសង់ ៥ឆ្នាំ ហើយនឹងប្រគល់ទៅឱ្យរាជរដ្ឋាភិបាលកម្ពុជាក្រោយពីដំណាក់កាលគ្រប់គ្រងនោះ ។ ទុនវិនិយោគនៃគម្រោងដំណាក់កាលទី១ មានទំហំប្រមាណ ៨៨០លានដុល្លារអាម៉េរិក ។

លោកស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូនកម្ពុជាមានប្រសាសន៍ថា គម្រោងសាងសង់ព្រលានយន្តហោះថ្មីនៅខេត្តសៀមរាបនេះមានសារសំខាន់ណាស់ ។ វានឹងជួយកម្ពុជាទទួលភ្ញៀវទេសចរអន្តរជាតិកាន់តែច្រើនដែលមកទស្សនាប្រាសាទអង្គរវត្ត។

អ្នកវិភាគបានលើកជាមតិថា គម្រោងព្រលានយន្តហោះថ្មីនេះមិនគ្រាន់តែនឹងជំរុញការអភិវឌ្ឍនៃវិស័យទេសចរណ៍ប៉ុណ្ណោះទេ ថែមទាំងនឹងជំរុញការអភិវឌ្ឍឧស្សាហកម្មពាក់ព័ន្ធផ្សេងៗទៀតនៃប្រទេសកម្ពុជាទៀតផង ៕ **ដោយម៉ៅ ភីងហ៊ី(ស៊ីនហួចិន)**

កិច្ចប្រជុំមិត្តអ្នកអាននៃសៀវភៅ "ស៊ី ជីនភីង : អភិបាលកិច្ចប្រទេសចិន" បារព្ធនៅប្រទេសអេមីរ៉ាតអារ៉ាប់រួម

នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០១៨ កិច្ចប្រជុំមិត្តអ្នកអាននៃសៀវភៅ "ស៊ី ជីនភីង : អភិបាលកិច្ចប្រទេសចិន" និងកម្មវិធី "សប្តាហ៍ពិព័រណ៍សៀវភៅចិន" បានប្រារព្ធនៅមជ្ឈមណ្ឌលវប្បធម៌ "ប៉មភ្លើង" ក្នុងប្រទេសអេមីរ៉ាតអារ៉ាប់រួម ។

ភ្ញៀវកិត្តិយសដែលចូលរួមក្នុងកិច្ចប្រជុំនិងពិព័រណ៍នេះបានលើកឡើងថាសៀវភៅ "ស៊ី ជីនភីង :អភិបាលកិច្ចប្រទេសចិន" នេះបានឆ្លើយសំណួរ "តើប្រទេសចិនមកពីកន្លែងណា? ហើយនឹងធ្វើដំណើរទៅកន្លែងណា?" ប្រវត្តិសាស្ត្រជាប្រភពនៃស្ថានភាពបច្ចុប្បន្ន ចំណែកអនាគតជាការបន្តនៃស្ថានភាពបច្ចុប្បន្ន ។ មានតែមានការយល់ដឹងអំពីបញ្ហា "ប្រទេសមួយមកពីកន្លែងណា" នេះទើបអាចស្វែងយល់អំពីការអភិវឌ្ឍនាពេលបច្ចុប្បន្ននៃប្រទេសនេះព្រមទាំងទិសដៅអភិវឌ្ឍន៍នាពេលអនាគតនៃប្រទេសនេះ ។

លោកហួ សែនយីស្មែល អ្នកសិក្សាស្រាវជ្រាវអំពីប្រទេសចិនដែលមកពីប្រទេសអេហ្ស៊ីបបានថ្លែងចំណាប់អារម្មណ៍ ផ្ទាល់ខ្លួនថា២៥ឆ្នាំមុនខ្ញុំបានជិះយន្តហោះទៅក្រុងប៉េកាំង ។ កាលនោះខ្ញុំយល់ឃើញថា ខ្ញុំមានការយល់ដឹងច្រើនអំពីប្រទេសចិនហើយអាចសរសេរ សៀវភៅមួយក្បាល ។ ប៉ុន្តែនៅពេលខ្ញុំ ទៅដល់ប្រទេសចិនទើបរកឃើញថា ខ្លួនខ្ញុំទើបចាប់ផ្តើមមានការយល់ដឹងអំពីប្រទេសនេះ។ សៀវភៅ "ស៊ី ជីនភីង : អភិបាលកិច្ចប្រទេសចិន" នេះបានឆ្លើយសំណួរជាច្រើនដែលខ្ញុំបានខិតខំគិតគូរអស់ពេលជាច្រើនឆ្នាំ ។ ដោយសារខ្ញុំធ្វើការជាអ្នកបកប្រែម្នាក់ខ្ញុំបានអានសៀវភៅនេះជាភាសាអារ៉ាប់និងភាសាអង់គ្លេស ដើម្បីសិក្សាស្រាវជ្រាវឱ្យបានកាន់តែស៊ីជម្រៅអំពីស្មារតីដ៏សម្បូរដែលត្រូវបង្កប់នៅក្នុងសៀវភៅនេះ។ វាជាសៀវភៅមួយក្បាលដែលគួរឱ្យមនុស្សម្នាក់ៗរួមទាំងអ្នកដឹកនាំប្រទេសអ្នកសិក្សាស្រាវជ្រាវនិងប្រជាជនសាមញ្ញយកមកអានដោយយកចិត្តទុកដាក់ ។

លោកហាលីហ្វូណាគីអ្នកសិក្សាស្រាវជ្រាវអំពីប្រទេសចិននៃប្រទេសអេមីរ៉ាតអារ៉ាប់រួមបានគូសបញ្ជាក់ថា គំនិតផ្តួចផ្តើម "ខ្សែក្រវាត់មួយនិងផ្លូវមួយ" ដែលលើកឡើងដោយឯកឧត្តមស៊ី ជីនភីងនោះ ស្របទៅនឹងតម្រូវការនៃការអភិវឌ្ឍរបស់ប្រទេសដ៏ច្រើន ។ ទន្ទឹមនឹងការបង្កើតទំនាក់ទំនងភាពជាដៃគូសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយរួមគ្នាធ្វើការអភិវឌ្ឍនិងដើរឆ្ពោះទៅកាន់អនាគត "ខ្សែក្រវាត់មួយនិងផ្លូវមួយ" នឹងអាចក្លាយទៅជាស្ពានមួយខ្សែសម្រាប់ពង្រឹងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរអេមីរ៉ាតអារ៉ាប់រួមនិងចិន៕ **(ស៊ីនហួចិន)**

ខេត្តយូនណានផ្តល់ប្រាក់បន្ថែមពិសេស៥០លានយ័នដើម្បីអនុវត្តន៍ "ផែនការទាក់ទាញធនធានមនុស្សយុវវ័យមួយពាន់នាក់"

ពេលថ្មីៗនេះ សាលារដ្ឋបាលខេត្តយូនណានបានផ្តល់ប្រាក់បន្ថែមពិសេសដល់ធនធានមនុស្សក្រុមទី១ដែលជាប់ឈ្មោះក្នុង "ផែនការទាក់ទាញធនធានមនុស្សយុវវ័យមួយ ពាន់នាក់" ។ យុវជនយុវនារី១០០នាក់ដែលជាប់ឈ្មោះក្នុង "ផែនការ ទាក់ទាញធនធានមនុស្សយុវវ័យមួយពាន់នាក់ " របស់ខេត្តយូនណានបានទទួលប្រាក់បន្ថែមសម្រាប់ការរស់នៅ និងការធ្វើ ការងារចំនួន៥សែនយ័នក្នុងមនុស្សម្នាក់ សរុបមានប្រាក់បន្ថែម ៥០លានយ័ន ។

គម្រោងទាក់ទាញធនធានមនុស្សយុវវ័យ ពិសេសជាគម្រោងមួយក្នុងចំណោមគម្រោងពិសេសចំនួន៧ នៃ "ផែនការទាក់ទាញធនធានមនុស្សយុវវ័យមួយពាន់នាក់" របស់យូនណាន។ គម្រោងនេះជាគម្រោងសំខាន់មួយរបស់ខេត្តយូនណានសម្រាប់ទាក់ទាញ និងនាំចូលធនធានមនុស្សយុវវ័យជាន់ខ្ពស់ ដើម្បីលើកកម្ពស់នូវសមត្ថភាពប្រកួតប្រជែង និងជំរុញការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ខេត្តយូនណានដោយអាស្រ័យលើធនធានមនុស្ស។ តាមផែនការដែលបានកំណត់ខេត្តយូនណាននឹងប្រើប្រាស់រយៈពេល៥ ឆ្នាំ ដើម្បីទាក់ទាញ និងនាំចូលធនធានមនុស្សយុវវ័យ១.០០០នាក់ដើម្បីបំពេញតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ៕ **(ស៊ីនហួចិន)**

ផ្នែកសំខាន់នៃស្ពានឆ្លងទន្លេមេគង្គតាមខ្សែរថភ្លើងចិន-ឡាវបញ្ចប់ការសាងសង់ជាស្ថាពរ

យប់ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨ សសរសំខាន់ចុងក្រោយនៃស្ពានឆ្លងទន្លេមេគង្គលួងប្រាបាងតាមខ្សែរថភ្លើងចិន-ឡាវ បានត្រូវចាក់បេតុងដោយជោគជ័យ។ នេះបានបង្ហាញឱ្យឃើញថាផ្នែកសំខាន់នៃស្ពានឆ្លងទន្លេមេគង្គតាមខ្សែរថភ្លើងចិន-ឡាវបានត្រូវបញ្ចប់ការសាងសង់ជាស្ថាពរ។

ស្ពានដ៏ធំនេះជាផ្នែកសំខាន់មួយនៃគម្រោងសាងសង់ខ្សែរថភ្លើងចិន-ឡាវ។ ស្ពាននេះមានប្រវែងសរុប១៤៥៨,៩ ម៉ែត្រ និងមានសសរធំចំនួន៣៤ដើម ៕

រូបថតដែលត្រូវបានផ្តិតយក កាលពីថ្ងៃទី១១ ខែកក្កដា បង្ហាញអំពី ការសាងសង់សំណង់ស្ពានលួងប្រាបាងនៃការដ្ឋានសំណង់កំណត់ផ្លូវដែកចិន និងឡាវ (ស៊ីនហួរ)

"តំបន់ច្នៃប្រឌិតវប្បធម៌ចិន-កម្ពុជា" ដែលវិនិយោគដោយសហគ្រាសខេត្តយូនណានបើកការដ្ឋានសាងសង់ជាផ្លូវការ

ពិធីចុះបឋមសិលាកសាង តំបន់ច្នៃប្រឌិតវប្បធម៌ចិន-កម្ពុជា (រូបថត ដោយ Yu Jiangning)

ថ្ងៃទី១៩ខែកក្កដាឆ្នាំ២០១៨ ជាខួបលើកទី៦០នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសចិននិងកម្ពុជា ។ គម្រោងតំបន់ច្នៃប្រឌិតវប្បធម៌ចិន-កម្ពុជា "ដែលធ្វើវិនិយោគដោយក្រុមហ៊ុនវិនិយោគវប្បធម៌ខេត្តយូនណាន-គ្រុបនោះ បានបើកការដ្ឋានសាងសង់ជាផ្លូវការក្នុងក្រុងវប្បធម៌អង្គរថ្មីនៅខេត្តសៀមរាបនៃប្រទេសកម្ពុជា ។

ខេត្តយូនណាន និងខេត្តសៀមរាបបានបង្កើតសម្ព័ន្ធមេត្រីភាព។ "តំបន់ច្នៃប្រឌិតវប្បធម៌ចិន-កម្ពុជា" នេះគឺជាគម្រោងដែលមានលក្ខណៈតំណាងមួយសម្រាប់អបអរសាទរខួបលើកទី៦០ នៃការបង្កើតទំនាក់ទំនងការទូតកម្ពុជា-ចិន។ គម្រោងនេះទទួលបន្ទុកអនុវត្តន៍ដោយក្រុមហ៊ុនវិនិយោគវប្បធម៌អន្តរជាតិអង្គរនៃក្រុមហ៊ុនវិនិយោគវប្បធម៌ខេត្តយូនណានគ្រុប ។

គួរបញ្ជាក់ថា តំបន់ច្នៃប្រឌិតវប្បធម៌នេះមានផ្ទៃក្រឡាសរុប៣,៣ ហិកតា រួមមានរោងល្ខោនស្នាមញញឹមអង្គរ ដែលអាចទទួលបានទស្សនិកជន ១.៥០០នាក់ កម្មវិធីសម្តែងសិល្បៈ "ស្នាមញញឹមអង្គរ" ថ្មីសារមន្ទីរជីវតាក្លាន់របៀងសិល្បៈចេនឡា មជ្ឈមណ្ឌលផ្លាស់ប្តូរវប្បធម៌ចិន-កម្ពុជា មជ្ឈមណ្ឌលពិព័រណ៍ផលិតផលច្នៃប្រឌិតវប្បធម៌និងមជ្ឈមណ្ឌលវប្បធម៌ម្ហូបអាហារដែលអាចទទួលបានទេសចរ១.២០០ នាក់ ។

តំបន់ច្នៃប្រឌិតវប្បធម៌នេះនឹងបង្ហាញជូនទេសចរអន្តរជាតិនូវប្រវត្តិសាស្ត្រដ៏យូរលង់វប្បធម៌ដ៏ក្រាស់ក្រែល និងទំនៀមទម្លាប់ប្រពៃណីដ៏ទាក់ទាញរបស់ប្រទេសកម្ពុជា ហើយនឹងអាចជាតំបន់វប្បធម៌ធំជាងគេបំផុតនៅប្រទេសកម្ពុជា។ តាមផែនការដែលបានកំណត់គម្រោងដំណាក់កាលទី១ នឹងអាចត្រូវបញ្ចប់ការសាងសង់និងដាក់ឱ្យប្រើប្រាស់នៅដើមឆ្នាំ២០២០៕

ដោយយូ ជាំងនីង